**កម្មភាព** ៖ **ហេតុអ្វីបានជាយើងប្រើសាប៊ូលាងដៃ?**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**វិទ្យាសាស្ត្រ**

បំណិនអនាម័យ (ទម្លប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(វិទ្យាសាស្ត្រ)** ប្រាប់ពីទម្លប់ល្អទាំងឡាយ មុន និងក្រោយពេលញុំាអាហារ បន្លែ ផ្លែឈើ ទឹកស្អាត ចូលបង្គន់អនាម័យ សម្អាតខ្លួនប្រាណ ។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "បិសាចចម្លែកតូចៗ" ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ចានក្រឡូម ដបទឹក (គ្រប់គ្រាន់សម្រាប់បំពេញតាមចានគោមនីមួយៗ) ម្សៅម្រេច សាប៊ូនៅក្នុងធុងតូចៗ និងធុងធំៗសម្រាប់ប្រមូលសាប៊ូនៅចុងក្រោយមេរៀន។

**ការរៀបចំ** ៖ ព្យាយាមពិសោធន៍មុនសិន ដើម្បីឱ្យច្បាស់ថាវាដំណើរការ ឬក៏អត់ ជាមួយនឹងម្រេចដែលអ្នកប្រើ។

**សេក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែង**ហេតុអ្វីបានជាយើងប្រើសាប៊ូលាងដៃ?**ជាមួយកូនៗទាំងអស់គ្នា។
2. សួរក្មេងៗ៖ ហេតុអ្វីបានជាការលាងដៃ មានសារៈសំខាន់? បាទ/ចាស ដើម្បីអនាម័យ។
3. ហេតុអ្វីបានជាត្រូវការប្រើប្រាស់សាប៊ូលាងដៃ និងទឹក ? បាទ/ចាសប្រើសាប៊ូដើម្បីកំចាត់មេរោគ។
4. ប្រាប់ក្មេងៗ៖ កូនៗនឹងធ្វើការពិសោធន៍ដើម្បីបង្ហាញថា ហេតុអ្វីបានជាត្រូវប្រើសាប៊ូលាងដៃ?
5. បែងចែកក្មេងៗទៅជាក្រុម ដែលមាន៤-៥នាក់ក្នុងមួយក្រុម ។

6. ចូរឱ្យក្មេង២នាក់តាមក្រុមនីមួយៗឡើងមកយកចានគោម ដបទឹក និងម្រេចខ្លះៗ។
7. ឱ្យក្មេងទី៣ ចាក់ទឹកចូលទៅក្នុងចានក្រគោម។
8. ឱ្យក្មេងទី៤ ស្រោចម្រេចចូលទៅក្នុងទឹក ។
9. ឱ្យក្មេងៗទាំងនោះដាក់ដៃឱ្យស្ងួតជាមុនសិន
10. បន្ទាប់មកឱ្យក្មេងៗដាក់ម្រាមដៃរបស់ពួកគេចូលទៅក្នុងទឹកក្នុងចាននោះ ។
11. ពិភាក្សាគ្នា ថានឹងមានរឿងអ្វីកើតឡើង ទៅលើម្រេច? ម្រិចនឹងអណ្តែតមកជាប់លើដៃធ្វើឱ្យប្រលាក់គក្រិចលើដៃជាមិនខាន (ក្មេងៗគួរតែកត់ត្រាទុកសួរថាមានរឿងអ្វីបានកើតឡើង)។
12. ឱ្យក្មេងចុងក្រោយក្នុងក្រុមនីមួយៗ (ក្មេងដែលមិនទាន់បានលេង) ឡើងទៅទទួលសាប៊ូ ។
13. ប្រាប់ក្មេងៗទាំងអស់ ឱ្យលាបសាប៊ូជុំវិញម្រាមដៃទាំងអស់របស់ពួកគេ បន្ទាប់មកលូកដៃចូលទៅក្នុងចានទឹកម្តងទៀត ។
14. ពិភាក្សាថាមានរឿងអ្វីកើតឡើងជាមួយនឹងម្រេចទាំងនោះ។ ដៃរបស់ក្មេងៗប្រាកដជាជ្រុះម្រេចចេញពីដៃ (ពួកគេគួរតែកត់ចំណាំ អ្វីទៅដែលបានខ្ចាតឆ្ងាយពីសាប៊ូ?) ។
15. សួរក្មេងៗថាតើហេតុអ្វីបានជាពួកគេគិតថាវាកើតឡើងបែបនេះ?
16. ពិភាក្សា ថាហេតុអ្វីបានជាត្រូវប្រើសាប៊ូ និងធ្វើឱ្យប្រាកដថាពួកគេយល់ដែលសាប៊ូអាចជួយជំរះភាពគក្រិច និងរបស់ដែលជាប់នៅលើដៃរបស់អ្នក។
17. ដើរជុំវិញជាមួយនឹងចានធំ ដើម្បីប្រមូលទឹកទាំងនោះ ។
18. ចូរឱ្យក្មេងៗបោះចោលសម្រាម និងទុកដាក់របស់របរទាំងអស់ឱ្យមានរបៀប។